**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

# ក្រសួងអភិវឌ្ឍន៍ជនបទ

Ministry of Rural Development



# ថវិកាប្រជាពលរដ្ឋ ២០២៤

# Citizen Budget Fiscal Year 2024

ខែមីនា ឆ្នាំ២០២៤

**១-ចក្ខុវិស័យ**

ធានាលើកកម្ពស់គុណភាព និងគុណតម្លៃ នៃជីវិត រស់នៅរបស់ប្រជាជនជនបទប្រកប ដោយបរិយាប័ន្ន ទាំងផ្នែកសេដ្ឋកិច្ច សង្គម និងវប្បធម៌។

**២-បេសកកម្ម**

ក្រសួងអភិវឌ្ឍន៍ជនបទត្រូវបានរាជរដ្ឋាភិបាល ប្រគល់បេសកម្មឱ្យដឹកនាំ និងគ្រប់គ្រង វិស័យអភិវឌ្ឍន៍ ជនបទនៃព្រះរាជាណាចក្រកម្ពុជា ដែលមានដែលមាន មុខងារនិងភារកិច្ចសំខាន់ៗ ដូចខាងក្រោម÷

- កំណត់គោលនយោបាយ និងយុទ្ធសាស្ត្រនៃការអភិវឌ្ឍន៍ជនស្របតាមកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាល
- លើកទិសដៅ ផែនការរយៈខ្លី មធ្យម និងវែង លើការងារអភិវឌ្ឍន៍ជនបទ ដើម្បីកែលម្អស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌របស់ប្រជារាស្ត្រជនបទទូទៅដោយរួមបញ្ចូលទាំងជនជាតិភាគតិចក្នុងព្រះរាជាណាចក្រកម្ពុជាឱ្យកាន់តែល្អប្រសើរឡើងកាត់បន្ថយជាបណ្តើរៗ នូវភាពក្រីក្រ និងភាពខុសគ្នារវាងអ្នកជនបទ និងអ្នកទីក្រុង
- ចូលរួមការកសាងនិងអភិវឌ្ឍន៍ប្រទេសជាតិក្នុងវិស័យអភិវឌ្ឍន៍ជនបទដោយកម្រិត សកម្មភាពការងារត្រឹមថ្នាក់គ្រួសារ ភូមិ និងឃុំក្នុងព្រះរាជាណាចក្រកម្ពុជា
- សិក្សាស្រាវជ្រាវប្រមូលផ្តុំ និងគ្រប់គ្រងទិន្នន័យ ព័ត៌មានស្ថិតិអំពីស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌នៅតំបន់ជនបទ នៃព្រះរាជាណាចក្រកម្ពុជា ដែលគិតទាំងភ្នំ តំបន់ខ្ពង់រាប និងវាលរាប
- អភិវឌ្ឍន៍ធនធានមនុស្សតាមរយៈការបណ្តុះបណ្តាលបច្ចេកទេស និងចំណេះដឹងដល់មន្ត្រីបុគ្គលិករាជការរបស់ក្រសួង
- រៀបចំបើកមជ្ឈមណ្ឌលបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈថ្នាក់ភូមិភាគដល់ប្រជារាស្ត្រជនបទតាមការចាំបាច់ និងតាមលទ្ធភាពជាក់ស្តែង
- អប់រំផ្សព្វផ្សាយ ដើម្បីលើកកម្ពស់ផលិតភាពនិងប្រាក់ចំណូលប្រចាំគ្រួសាររបស់ប្រជាពលរដ្ឋ ដោយពឹងផ្អែកលើការស្រាវជ្រាវបច្ចេកទេសអភិវឌ្ឍន៍ជនបទ
- ធ្វើទំនាក់ទំនងសម្របសម្រួល និងសហប្រតិបត្តិការជាមួយបរទេស អង្គការអន្តរជាតិ មានការពាក់ព័ន្ធព្រមទាំងប្រជារាស្ត្រមូលដ្ឋានដើម្បីធ្វើការអភិវឌ្ឍន៍ជនបទប្រកប ដោយចីរភាព
- គ្រប់គ្រង ដឹកនាំ និងទទួលខុសត្រូវក្នុងការអនុវត្តកម្មវិធីអភិវឌ្ឍន៍ជនបទចម្រុះថ្នាក់គ្រួសារ ភូមិឃុំដែលរួមមានផ្លូវជនបទ ផ្គត់ផ្គង់ទឹកជនបទ ថែទាំសុខភាពបឋម អភិវឌ្ឍន៍សហគមន៍ និងអភិវឌ្ឍន៍សេដ្ឋកិច្ចជនបទ ដោយសហការណ៍ជាមួយស្ថាប័ន ពាក់ព័ន្ធ
- ជំរុញការរៀបចំ និងពង្រឹងរចនាសម្ព័ន្ធអភិវឌ្ឍន៍ជនបទគ្រប់ជាន់ថ្នាក់ ជាពិសេស គណៈកម្មាធិការអភិវឌ្ឍន៍ជនបទនៅថ្នាក់មូលដ្ឋាន។

ក្នុងឆ្នាំ២០២៤នេះ ក្រសួងអភិវឌ្ឍន៍ជនបទនៅបន្តអនុវត្តកម្មវិធីចំនួន ០៤ ដដែល ដូចខាងក្រោម÷

១-កម្មវិធីទី១ ÷ អភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត និងគមនាគមន៍
២-កម្មវិធីទី២ ÷ កែលម្អលក្ខខណ្ឌនៃការរស់នៅរបស់សហគមន៍ជនបទ
៣-កម្មវិធីទី៣ ÷ ពិពិធកម្មសកម្មភាពសេដ្ឋកិច្ចជនបទ
៤-កម្មវិធីទី៤ ÷ ពង្រឹងសេវាគាំទ្ររដ្ឋបាល និងកិច្ចការទូទៅ

**៣-គោលដៅសូចនាករលទ្ធផលក្នុងឆ្នាំ២០២៤ និងថវិកាឆ្នាំ២០២៤**

ដើម្បីសម្រេចបានជោគជ័យ ក្រសួងអភិវឌ្ឍន៍ជនបទបានកំណត់គោលដៅ សូចនាករលទ្ធក្នុងឆ្នាំ និងក្របខណ្ឌថវិកាឆ្នាំ២០២៤ សរុបចំនួន **៣៦០ ៨២៣ លានរៀល** ទៅតាមកម្មវិធីនីមួយៗដូចខាងក្រោម÷

## កម្មវិធីទី១ ÷ អភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត និងគមនាគមន៍

ដើម្បីវាស់វែងលទ្ធផលសម្រេចបានកម្មវិធីទី១ បង្កើតសូចនាករលទ្ធផលក្នុងឆ្នាំគន្លឹះ ចំនួន ០៤ ដូចខាងក្រោម÷



| គោលបំណងកម្មវិធី | សូចនាករគន្លឹះ | គោលដៅ (លទ្ធផលក្នុងឆ្នាំ) |
|---|---|---|
| **គោលបំណងកម្មវិធីទី១÷** ឱ្យប្រសើរស្ថានភាពផ្លូវជនបទតាមរយៈការបង្កើនគុណភាព និងការតភ្ជាប់ផ្លូវតំបន់ជនបទធានាការប្រើប្រាស់គ្រប់រដូវកាល ដើម្បីលើកកម្ពស់ស្ថានភាពសេដ្ឋកិច្ច និងសង្គមកិច្ច | **សូចនាករទី១÷** ប្រវែងផ្លូវជនបទដែលត្រូវបានស្ថាបនាដោយក្រាលកៅស៊ូ DBST (គ.ម) | ៨៣,៥ គ.ម |
| | **សូចនាករទី២÷**ប្រវែងផ្លូវជនបទដែលត្រូវបានស្ថាបនាបេតុង(គ.ម ) | ២០,៦៤ គ.ម |
| | **សូចនាករទី៣÷**ប្រវែងផ្លូវជនបទដែលត្រូវបានស្ថាបនាដោយក្រាលល្បាយគ្រួស (គ.ម) | ១០៦.៣៦ គ.ម |
| | **សូចនាករទី៤÷** ប្រវែងផ្លូវជនបទដែលត្រូវបានថែទាំជាលក្ខណៈខួប , ប្រចាំ នឹងបន្ទាន់ (គ.ម ) | ៤ ២០៤,៤គ.ម |

ដើម្បីសម្រេចបានកម្មវិធីទី១ មានតម្រូវការថវិកាដូចខាងក្រោម÷

*កម្មវិធីទី១ =**២៩០ ៤៦៧,៨ លានរៀល**
-រដ្ឋបាលកណ្តាល =២៧១ ១៦៨,៨ លានរៀល
-មន្ទីរអ.ជ.ប រាជធានី ខេត្ត = ១៩ ២៩៩ លានរៀល




*កម្មវិធីទី១ ថវិកាឆ្នាំ២០២៤ កើនឡើង ៤% ធៀបនឹងថវិកាឆ្នាំ២០២៣*

## កម្មវិធីទី២÷កែលម្អលក្ខខណ្ឌនៃការរស់នៅរបស់សហគមន៍ជនបទ

ដើម្បីវាស់វែងលទ្ធផលសម្រេចបានកម្មវិធីទី២ បង្កើតសូចនាករលទ្ធផលក្នុងឆ្នាំគន្លឹះ ចំនួន ០៤ ដូចខាងក្រោម÷

| គោលបំណងកម្មវិធី | សូចនាករគន្លឹះ | គោលដៅ (លទ្ធផលក្នុងឆ្នាំ) |
|---|---|---|
| **គោលបំណងកម្មវិធីទី២÷** លើកកម្ពស់លក្ខខណ្ឌ នៃការរស់នៅរបស់សហគមន៍ជនបទ តាមរយៈការផ្តល់សេវាផ្គត់ផ្គង់ទឹកស្អាត និងអនាម័យ ។ | **សូចនាករទី១÷** ចំនួនអណ្តូងទឹកដែលត្រូវបានសាងសង់ | ៣៤០ អណ្តូង |
| | **សូចនាករទី២÷** ចំនួនស្រះទឹកដែលត្រូវបានសាងសង់ | ៥ស្រះ |
| | **សូចនាករទី៣÷** ចំនួនប្រព័ន្ធចែកចាយទឹកស្អាតខ្នាតតូចដែលត្រូវបានសាងសង់ | ៦ប្រព័ន្ធ |
| | **សូចនាករទី៤÷**ចំនួនបង្គន់អនាម័យដែលត្រូវបានសាងសង់ | ៣ ១១៤ បង្គន់ |

ដើម្បីសម្រេចបានកម្មវិធីទី២  មានតម្រូវការថវិកាដូចខាងក្រោម÷

*កម្មវិធីទី២ = **១១ ៧៥២,៥** **លានរៀល**

-រដ្ឋបាលកណ្ដាល = ៩ ៦២៩,៧ លានរៀល

-មន្ទីរអ.ជ.ប រាជធានី ខេត្ត = ២ ១២២,៨ លានរៀល




*កម្មវិធីទី២ ថវិកាឆ្នាំ២០២៤ កើនឡើង **៣.៥%** ធៀបនឹងថវិកាឆ្នាំ២០២៣*

## កម្មវិធីទី៣÷ពិពិធកម្មសកម្មភាពសេដ្ឋកិច្ចជនបទ

ដើម្បីវាស់វែងលទ្ធផលសម្រេចបានកម្មវិធីទី៣ បង្កើតសូចនាករលទ្ធផលក្នុងឆ្នាំគន្លឹះ ចំនួន ០៣ ដូចខាងក្រោម÷

| គោលបំណងកម្មវិធី | សូចនាករគន្លឹះ | គោលដៅ (លទ្ធផលក្នុងឆ្នាំ) |
|---|---|---|
| **គោលបំណងកម្មវិធីទី៣÷** លើកកម្ពស់ជីវភាពគ្រួសារនៅជនបទតាមរយៈការធ្វើពិពិធកម្មសេដ្ឋកិច្ច,ការបណ្ដុះបណ្ដាលជំនាញមូលដ្ឋាន និងវិជ្ជាជីវៈ,ការបង្កើតមុខរបរ, សហគ្រិនភាព និងចលនាភូមិគំរូ រួមទាំងការអភិវឌ្ឍ និងអភិរក្សជនជាតិដើមភាគតិច ។ | **សូចនាករទី១÷** ចំនួនសិក្ខាកាមដែលទទួលបានការបណ្ដុះបណ្ដាលអំពីវិធីសាស្ត្រធ្វើសាប៊ូ.អ៊ុតសក់, ជួសជុលម៉ូតូ.ជួសជុលម៉ាស៊ីនកសិកម្មនិងធ្វើជី កំប៉ុស្ដ កុំព្យូទ័រ , ភាសាអង់គ្លេស | ១ ៨៩៤ នាក់ |
| | **សូចនាករទី២÷**ចំនួនសិក្ខាកាមដែលទទួលបានការបណ្ដុះ បណ្ដាលអំពីវិធីសាស្ត្របច្ចេកទេស ដាំបន្លែ,ចិញ្ចឹមសត្វ, ចញ្ចឹមត្រី | ៨០០ នាក់ |
| | **សូចនាករទី៣÷** ចំនួនភូមិជនជាតិដើមភាគតិចត្រូវបានកំណត់អត្តសញ្ញាណ | ៨ ភូមិ |

ដើម្បីសម្រេចបានកម្មវិធីទី៣  មានតម្រូវការថវិកាដូចខាងក្រោម÷

*កម្មវិធីទី៣ = **៣ ៣៩៤,៩** **លានរៀល**

-រដ្ឋបាលកណ្ដាល = ២ ៦៨៩,៥ លានរៀល

-មន្ទីរអ.ជ.ប រាជធានី ខេត្ត = ៧០៥,៤ លានរៀល






*កម្មវិធីទី៣ ថវិកាឆ្នាំ២០២៤ កើនឡើង **៣,៩%** ធៀបនឹងថវិកាឆ្នាំ២០២៣*

## កម្មវិធីទី៤÷ពង្រឹងសេវាគាំទ្ររដ្ឋបាល និងកិច្ចការទូទៅ

ដើម្បីវាស់វែងលទ្ធផលសម្រេចបានកម្មវិធីទី១ បង្កើតសូចនាករលទ្ធផលក្នុងឆ្នាំគន្លឹះ ចំនួន ០៣ ដូចខាងក្រោម÷

| គោលបំណងកម្មវិធី | សូចនាករគន្លឹះ | គោលដៅ (លទ្ធផលក្នុងឆ្នាំ) |
|---|---|---|
| **គោលបំណងកម្មវិធីទី៤÷** បង្កើនស័ក្តិសិទ្ធិភាព, ប្រសិទ្ធភាព, គណនេយ្យភាព និងតម្លាភាព នៃការអនុវត្តថវិកាកម្មវិធី ដើម្បីពង្រឹងស្ថាប័ន។ | **សូចនាករទី១÷**ភាពទាន់ពេលនៃការលើកគម្រោងថវិកា | គម្រោងថវិកាត្រូវបានរៀបចំស្របតាមកាលកំណត់នៃសារាចរណែនាំ ស្ដីពីការរៀបចំសេចក្ដីព្រាងច្បាប់ស្ដីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់ គ្រងប្រចាំឆ្នាំ |
| | **សូចនាករទី២÷**អត្រានៃការអនុវត្តថវិកាសមិទ្ធកម្មរបស់អង្គភាពក្រោមឱវាទក្រសួង | ១០០% |
| | **សូចនាករទី៣÷**ភាពទាន់ពេលនៃការរៀបចំរបាយការណ៍សមិទ្ធកម្ម | របាយការណ៍សមិទ្ធកម្មត្រូវបានរៀបចំស្របតាមកាលកំណត់នៃសារាចរណែនាំស្ដីពីការអនុវត្តច្បាប់ស្ដីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងប្រចាំឆ្នាំ |

ដើម្បីសម្រេចបានកម្មវិធីទី៤  មានតម្រូវការថវិកាដូចខាងក្រោម÷

*កម្មវិធីទី៤ = **៥៥ ២០៧,៨** **លានរៀល**

-រដ្ឋបាលកណ្ដាល = ២៦ ២៣៤ លានរៀល

-មន្ទីរអ.ជ.ប រាជធានី ខេត្ត = ២៨ ៩៧៣,៨ លានរៀល




*កម្មវិធីទី៤ ថវិកាឆ្នាំ២០២៤ កើនឡើង **៩,១%** ធៀបនឹងថវិកាឆ្នាំ២០២៣*



## ៤-គម្រោងចំណាយសម្រាប់ឆ្នាំ២០២៤




- **កម្មវិធីទី១** អភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត និងគមនាគមន៍ មាន ៨១% នៃថវិកាឆ្នាំ២០២៤
- **កម្មវិធីទី២** កែលម្អលក្ខខណ្ឌនៃការរស់នៅរបស់សហគមន៍ជនបទ មាន ៣% នៃថវិកាឆ្នាំ២០២៤
- **កម្មវិធីទី៣** ពិពិធកម្មសកម្មភាពសេដ្ឋកិច្ចជនបទ មាន ១% នៃថវិកាឆ្នាំ២០២៤
- **កម្មវិធីទី៤** ពង្រឹងសេវាគាំទ្ររដ្ឋបាល និងកិច្ចការទូទៅមានថវិកា ១៥% នៃថវិកាឆ្នាំ២០២៤ ។




*ថវិកាឆ្នាំ២០២៤ កើនឡើងចំនួន **៤,៨%** ធៀបនឹងថវិកាឆ្នាំ២០២៣*



អាសយដ្ឋាន÷ ដីឡូត៍លេខ ៧៧១-៧៧៣ មហាវិថីព្រះមុនីវង្ស សង្កាត់បឹងត្របែក ខណ្ឌចំការមន រាជធានីភ្នំពេញ ទូរស័ព្ទលេខ: +៨៥៥ ១២ ៦៦៩ ៥៣៥
គេហទំព័រ: www.mrd.gov.kh